# រឿង មហាចោរនៅទល់ដែន

## ភាគទី១៤

ក្រោយពីរាត្រីកំសត់ដែលសម្បូរទៅដោយព្រឹត្តិការណ៍ចំលែកៗ ដែលបោះចំណុចធំៗ លើជីវិតនាង នាងទេវីវិយោគសោកាយ៉ាងខ្លាំងក្រៃអនេកៗ ស្រ្តីអស់កម្លាំងពន់ប្រមាណ ដោយពុំបានចូលនិទ្រាក៏តិចតួចសោះៗ ឪពុកនាងស្លាប់ នាងបានប្រឹងប្រែងទុកដាក់ជាស្រេចបាច់អស់ហើយៗ តែទុក្ខមួយថ្មីទៀតដែលមានទម្ងន់ធ្ងន់ក្រៃណាមកគ្របដន្តប់នាងថែម គឺទុក្ខព្រាត់ស្វាមីជាទីស្នេហាៗ មាណវីរង់ចាំស្ងួនភ្ងាតាំងពីយប់អស្ចារ្យនោះមក រួចនាងត្រូវរង់ចាំទៅមុខទៀតៗ ចាំៗ ... ឱ! ចាំដោយពុំដឹងមានរឿងអ្វី ចាំដោយពុំដឹងអ្នកទៅណា ចាំដោយពុំដឹងហេតុអ្វីបានជាបាត់ម្ល៉េះ ចាំមួយថ្ងៃជាពីរថ្ងៃ ចាំមួយខែជាពីរខែ... ចាំៗ ចាំរងកម្មរហូតៗ

ក្រោយមក ដោយពុំឈ្នះនឹងចាំ នាងបានឲ្យនាងភួងជាមាតាទៅស៊ើបសួរគេ ទើបនាងដឹងថា ប្តីកល្យាណអ្នកមានដំនើរទៅឆ្ងាយណាស់ទៅហើយៗ នាងយំ យំជានិច្ច ត្បិតជីវិតនាងជាជីវិតសម្រាប់តែយំទៅហើយៗ ឱ! ប្រុសប្រសើរ! អ្នកទៅ ទៅក៏ទៅចុះ តែទៅដោយគ្មានដំណឹង ទៅដោយផ្ងើកន្តើយ ហាក់ដូចគ្មាននាងសោះក្នុងជីវិតរបស់ប្រុសតែមួយនេះៗ គេទៅ .. ឱ! គេទៅ ពាក្យនេះអីក៏មានជម្រៅក្រៃម្ល៉េះ? គេទៅបាត់ ... ឱ! ពាក្យនេះធ្វើឲ្យព្រឺសព្វសាច់អីម្ល៉េះទេ បាត់ស្ងាត់សូន្យៗលើកពផែនដី សូន្យក្នុងភូមិ សូន្យពីចក្ខុនាងៗ ពុំងានឹកស្តាយស្តាយត្រង់មុនទៅស្រីពុំដឹង ខានមិនបានមើលមុខប្រុសឲ្យជាក់ច្បាស់ ដើម្បីចាំទុកឲ្យច្បាស់ក្នុងចិត្ត ... ស្តាយត្រង់ពុំបាននិយាយគ្នា លាគ្នា ចាប់ដៃគ្នាជាចុងបង្ហើយៗ

ជីវិតឥតគូ ជាជីវិតសាបសូន្យ ជីវិតធេងធោង គ្មានគោល គ្មានប៉ោលទេ គ្មានត្រើយ គ្មានទីដៅ គ្មានអុត្តមគតិ ជាជីវិតកំព្រា រង៉ោសង្វេគៗ គឺក្នុងគ្រាព្រាត់នេះហើយ ដែលមនុស្សមានមនោគតិច្រើនៗ រហូតដល់ទៅគ្មានវង្វាស់វង្វាល់ៗ គឺក្នុងគ្រាព្រាត់គ្នានេះហើយដែលមនុស្សមានមនោសញ្ចេតនាគ្រប់បែប គ្រប់យ៉ាងឥតគណនាបានឡើយៗ ខ្យល់ដែលបក់ បក់មកប៉ះសាច់ គឺរលកនៃចិត្តស្នេហាដែលមកដាស់អារម្មណ៍ឲ្យនឹកឃើញអនុស្សាវរីយ៍ចាស់ ដែលធ្លាប់នៅជាមួយគ្នាៗ ស្លឹកឈើដែលជ្រុះ ជ្រុះលើសន្តានចិត្តគូកំសត់ ធ្វើឲ្យនាងនឹកស្ទើររលេះរលួយអស់ប្រមាត់បេះដូងៗ ភ្លៀង ផ្គរ រន្ទះ ជាតុទាំងនេះញាំញីទឹកចិត្តឲ្យខ្លួលខ្វាញ់ដែល

អត្ថបទដោយ៖ មាស សុភាព

ទាញទឹកភ្នែកឲ្យហូររហាមជានិច្ច។ សត្វដែលយំ យំក្នុងទ្រូងរៀបរាប់ទុក្ខសុខរបស់គូសង្សារដែលព្រាត់ទៅម្នាក់ឯង។ អំពិលអំពែកដែលហើរៗ ពាយមាយ ហើរពេញភ្នែកជនដែលស្រលាញ់ដែលនឹក។

នាងទេវីនឹកដល់ប្រុសខ្លាំងពេក ទៅជាស្រមៃឃើញអ្នកកាន់ទ័ពដើរកាត់ព្រៃលំបាកវេទនាឥតដេកពួន ឥតបាយទឹក។ ស្រីស្រងេះស្រងោចគ្រវីក្បាលថា៖ *ឱ! គេមានការធ្វើច្រើនណាស់ គេពុំមានពេលនឹកនាងដូចនាងនឹកគេទេ។ ការគេ បំភ្លេចគេ។ ចំនែកនាងវិញ នាងមានការដែរ គឺលក់ដូរអីវ៉ាន់ មានដូង ស្វា ម្ទូ សាច់ត្រី ស្រូវ អង្ករជាដើម ដើម្បីចិញ្ចឹមជីវិតជាមួយនាងកួង តែក្នុងការនីមួយៗ ក្នុងវត្ថុនីមួយៗ មានទឹកចិត្តស្នេហាប្ដីលាយទៅជាមួយផងដែលបណ្ដាលឲ្យនាងនឹកគេជានិច្ច។ គិតទៅចិត្តប្រុសឆាប់ដាច់ពីស្រីណាស់។

នឹកឃើញដូច្នោះ នាងយំម្នាក់ឯង។ ថ្ងៃមួយព្រះអាទិត្យរះជ្រះស្រឡះមេឃ នាងទេវីកំពុងរៀបចំផ្ទះ ស្រាប់តែនៅមាត់ទ្វារនាងភ្ញាក់ខ្លួនព្រើតមុខឡើងស្លាំងដោយឃើញកាមាជាប្អូនដែលសើចរកនាងយ៉ាងក្អាកក្អាយដូចមុន។ ទេវីភ័យញ័រអស់សព្វសព៌ាង្គ។

- ម៉េចសុខសប្បាយជាទេ ?

ថាហើយ កាមាចូលជិតស្រីដែលថយក្រោយក្រាក។

- សុខនិងទុក្ខមានជាធម្មតា!

បុរសអង្គុយលើកៅអីយ៉ាងខែងញញឹមស្រស់។

- ខ្ញុំមកនេះមានការបន្តិច។
- ការអី ?
- ខ្ញុំសូមជម្រាបថា បងមានន្ទស្លាប់ហើយ !
- យី ! អីបងមានន្ទស្លាប់ ?

នារីយំខ្សឹកខ្សួល បន្តពាក្យទៅទៀតថា

អត្ថបទដោយ៖ មាស សុភាព

- អីបងមានន្ទស្លាប់ ! ឱបង ! ប្អូនមុខជាស្លាប់ផងហើយ។

  កាមាសើច នារីស្ទើរទន់ជង្គង់ អង្គុយចុះលើក្តារ។

- ទេ! អ្នកមិនត្រូវស្លាប់ទេ។ ដូចអ្នកជ្រាបស្រាប់ហើយ។ បងមានន្ទបានផ្តាំថា ឲ្យខ្ញុំជួយបីបាច់រក្សាអ្នក។ ក្នុងពេលនេះដំណឹងប្រាកដ គឺមានន្ទស្លាប់បាត់ទៅហើយ។ គាត់ស្លាប់ព្រោះគាត់ជាមនុស្សអាក្រក់ឃោរឃៅ ចិត្តឫស្យាណាស់ កាប់សម្លាប់មនុស្សរាប់រយពាន់នាក់ដុតផ្ទះសម្បែងគេ ដែលជាមនុស្សស្លូតត្រង់ បង្រ្កាសពង្រ្ទាត់ប្រពន្ធកូនគេ លួចប្លន់គេឯងក្នុងព្រៃ។ ថ្ងៃនេះខ្ញុំសូមចិត្តអ្នក សូមនិយាយនឹងអ្នកឲ្យអស់ទៅចុះ គឺខ្ញុំសូមដណ្តឹងអ្នកជាភរិយាស្មោះស្ម័គ្រដើម្បីរក្សាអ្នកតរៀងទៅ។ តើអ្នកមានយោបល់យ៉ាងណា ?

- ទេ។ សូមទោសលោកចុះ ខ្ញុំជាស្រីមេម៉ាយហើយ។
- អ្នក។ ស្តាប់ឲ្យបាន ! ខ្ញុំពុំបានធ្វើបាបអ្នកទេ គឺខ្ញុំបម្រុងយកអ្នកធ្វើជាប្រពន្ធពិត។ របស់ខ្ញុំព្រោះថា កាលពីបងមានន្ទនៅរស់ ខ្ញុំក៏ពុំដែលមានពាក្យអ្វីដូច្នេះដែរ តែបើឥឡូវបងមានន្ទស្លាប់បាត់បង់ជីវិតទៅហើយ គប្បីពាក្យស្នើរបស់ខ្ញុំបានសំរេចផងដែរ។ អ្នកនៅទំនេរធ្វើអ្វី នាំឲ្យសត្រូវមើលងាយទេ។
- ខ្ញុំទម្ងន់ជិតគ្រប់ខែទៅហើយ។
- មិនអីទេ កូនបងមានន្ទក៏ដូចកូនខ្ញុំដែរ។ ខ្ញុំជានាបីបាច់រក្សាកូននេះឲ្យដូចកូនខ្ញុំបង្កើត។
- ខ្ញុំកំពុងមានទុក្ខព្រួយនឹងប្តីខ្ញុំខ្លាំងណាស់។
- កាលណាអ្នករៀបការនឹងខ្ញុំទៅ ទុក្ខនេះនឹងវិនាសទៅឯងហើយ។
- ខ្ញុំជាស្រីមេម៉ាយទៅហើយ។
- រឿងនេះខ្ញុំគ្មានប្រកាន់អ្វីទេ។ ខ្ញុំដឹងថាអ្នកមេម៉ាយហើយ!
- ម្តេចលោកមិនគិតទៅរករៀបការនឹងគេឯទៀតទៅ ?
- ក្នុងជាតិនេះខ្ញុំបានសន្មតយ៉ាងដាច់ខាតក្នុងចិត្តថា ខ្ញុំស្រលាញ់តែអ្នកមួយទេ។ ហេតុនេះខ្ញុំសូមប្តូរជីវិតនឹងអ្នកតែមួយ។
- សូមលោកកុំស្រលាញ់ខ្ញុំ ខ្ញុំជាមនុស្សអភ័ព្វណាស់ . . . ។

អត្ថបទដោយ៖ មាស សុភាព

- វាសនាមនុស្សមើលមិនឃើញទេ។ តែទោះអក់ព្វយ៉ាងណាក៏ខ្ញុំសុខចិត្តលំបាកវេទនាវេគ្រោះជាមួយដែរ។
- ខ្ញុំមិនចង់បានប្ដីទៀតទេ។ អាណិតខ្ញុំទៅ។

(សូមរង់ចាំតាមដានភាគទី១៥ នៅសប្ដាហ៍ក្រោយ)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព